**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ ១៤៦៩ ......បទ..........................

# សេចក្ដីបំភ្លឺ

## ទាក់ទងនឹងតែមប្រៃសណីយ៍ មានទង់ជាតិកម្ពុជា និង ទង់ជាតិវៀតណាម ភ្ជាប់គ្នា

នៅក្នុងអត្ថបទព័ត៌មាន ក្រោមចំណងជើងថា "**បណ្ដាញសង្គមហ្វេសប៊ុក បង្ហោះតែមប្រៃសនីយ៍ មានទង់ជាតិកម្ពុជា វៀតណាមភ្ជាប់គ្នា**" របស់សារព័ត៌មាន VOD ចុះផ្សាយក្នុងវេបសាយ www.vodhotnews.com កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៤ កន្លងមក មានការលើកឡើងនូវព័ត៌មានមួយចំនួន ដែលអាចនាំដល់ការភ័ន្តច្រឡំអំពីករណីតែមប្រៃសណីយ៍ដូចបានលើកឡើងខាងលើនេះ។ ដើម្បីចៀសវាងការភ័ន្តច្រឡំណាមួយទាក់ទងនឹងករណីខាងលើនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមធ្វើការបំភ្លឺ ជូនសាធារណជនទាំងឡាយបានជ្រាប ដូចតទៅ៖

1. តែមប្រៃសណីយ៍ មានទង់ជាតិកម្ពុជា-វៀតណាមភ្ជាប់គ្នា ត្រូវបានបោះពុម្ព និងដាក់ឲ្យប្រើប្រាស់ក្នុងសេវាកម្មប្រៃសណីយ៍ តាំងពីឆ្នាំ២០០៧ ដើម្បីអបអរ "ខួបអនុស្សាវរីយ៍លើកទី៤០ ថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-វៀតណាម" គឺមិនមែនទើបតែត្រូវបានបោះពុម្ពកាលពីឆ្នាំ២០១៣ ដូចការលើកឡើងក្នុងអត្ថបទរបស់ VOD ឡើយ។
2. ការបោះពុម្ព និងដាក់ឲ្យប្រើប្រាស់តែមប្រៃសណីយ៍ដូចខាងលើនេះ ជារឿងធម្មតាក្នុងទំនាក់ទំនងអន្តរជាតិ ដែលប្រទេស ២ ប្រារព្ធសកម្មភាពមួយចំនួនរួមគ្នា អបអរសាទរខួបអនុស្សាវរីយ៍ធំៗ នៃទំនាក់ទំនងការទូត ក្នុងនោះមានការបោះពុម្ពតែមប្រៃសណីយ៍ ដោយមានដាក់ទង់ជាតិ នៃប្រទេសទាំងពីរជាប់គ្នា។ កន្លងទៅក៏មានតែមស្រដៀងគ្នានេះត្រូវបានបោះពុម្ពដើម្បីអបអរសាទរខួបលើកទី ៦០ ថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-អាមេរិក, ខួបលើកទី ៥០ ថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-ចិន, និងខួបលើកទី៤០ របស់អាស៊ានផងដែរ។
3. ប្រទេសវៀតណាម ជាសមាជិកអាស៊ានដូចកម្ពុជាដែរ ហើយនៅដំណាច់ឆ្នាំ២០១៥ខាងមុខ ប្រទេសសមាជិកអាស៊ានទាំង ១០ នឹងក្លាយជាសហគមន៍តែមួយ ដែលនឹងត្រូវចែករំលែកវាសនារួមគ្នា។ មាត្រា២ នៃធម្មនុញ្ញអាស៊ាន ចែងថា អាស៊ាន និងរដ្ឋសមាជិកត្រូវអនុវត្តឲ្យស្របតាមគោលការណ៍ "ចូលរួមការប្ដេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់... ភាពរួមបញ្ចូលគ្នា និងភាពមិនរើសអើង..."។
4. នៅលើពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជាយើងផងដែរ ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា នយោបាយរើសអើង ប្រកាន់ពូជសាសន៍ ជានយោបាយដ៏គ្រោះថ្នាក់បំផុត។ មាត្រា៥៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា "...ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។..."។ នយោបាយរស់នៅជាមួយប្រទេសជិតខាងដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការគោរពគ្នាទៅវិញទៅមក បានរួមចំណែកយ៉ាងសំខាន់ និងមិនអាចខ្វះបាន ក្នុងការស្តារ កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងរយៈពេល ៣៥ ឆ្នាំកន្លងមកនេះ បន្ទាប់ពីប្រទេសយើង ត្រូវខ្ទេចខ្ទាំដោយសារសង្គ្រាម និងអំពើប្រល័យពូជសាសន៍។

**រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤**

កាច់ជ្រុងវិថីលេខ ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៨៨០៩/៤២៨២៨៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៨៨០៩